ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# សេចក្តីជូនដំណឹង
# ស្តីពី
# ការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា
# ឱ្យចូលបម្រើការងារនៅលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់និស្សិត និង សាធារណជន មេត្តាជ្រាបថា ក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវការជ្រើសរើសបេក្ខភាពដែលមានចំណេះដឹងនិងជំនាញផ្នែកច្បាប់ និងផ្នែកបច្ចេកវិទ្យាព័ត៌មាន ដើម្បីចូលបម្រើការងារពេញម៉ោងជាបុគ្គលិកជាប់កិច្ចសន្យា នៅលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ដែលបេក្ខជន ឬបេក្ខនារី ត្រូវមានគុណវុឌ្ឍិ ដូចខាងក្រោម÷

## ក.លក្ខខណ្ឌទូទៅ

- មានសញ្ជាតិខ្មែរ
- មានអាយុយ៉ាងតិច ១៨ ឆ្នាំ
- មានសញ្ញាបត្របរិញ្ញាបត្រឡើងទៅពាក់ព័ន្ធនឹងជំនាញនីមួយៗ
- មានចំណេះដឹងទាំងសរសេរនិងនិយាយជា ភាសាអង់គ្លេស និង/ឬភាសាបារាំង ឬភាសាបរទេសផ្សេងៗទៀតបានល្អ
- គ្រប់គ្រងពេលវេលាបានល្អ អាចធ្វើការងារក្រោមសម្ពាធ មានទំនួលខុសត្រូវ បុរេសកម្ម និងយកចិត្តទុកដាក់ចំពោះការងារ (attention to details)
- មានអត្តចរិតនិងសីលធម៌រស់នៅល្អ ពុំធ្លាប់ជាប់ទោសពីបទឧក្រិដ្ឋ ឬមជ្ឈិម
- មានចំណេះដឹងផ្នែកកុំព្យូទ័រ (Microsoft Office, Internet and E-mail, និង Toolsផ្សេងៗ)។

## ខ.លក្ខខណ្ឌជាក់លាក់តាមជំនាញ

### ខ.១.ជំនាញផ្នែកច្បាប់

- មានបទពិសោធន៍ការងារពាក់ព័ន្ធនឹងជំនាញផ្នែកច្បាប់យ៉ាងតិច ២ឆ្នាំ ជាអាទិ៍÷ ការផ្តល់មតិប្រឹក្សាច្បាប់, ការតាក់តែងលិខិតបទដ្ឋានគតិយុត្ត, ការវិភាគនិងស្រាវជ្រាវច្បាប់ ជាដើម
- មានបទពិសោធន៍ផ្នែករដ្ឋបាល។

### ខ.២.ជំនាញផ្នែកបច្ចេកវិទ្យាព័ត៌មាន

- មានបទពិសោធន៍ការងារពាក់ព័ន្ធនឹង iOS Development ឬ Android Development ឬ Web Development។

**គ. វិញ្ញាសាប្រឡង**

- វិញ្ញាសាសរសេរ÷ ចំណេះដឹងទូទៅ, ចំណេះដឹងជំនាញពាក់ព័ន្ធ និងភាសាអង់គ្លេស
- វិញ្ញាសាសម្ភាសផ្ទាល់មាត់÷ សម្រាប់តែបេក្ខជនដែលបានប្រឡងជាប់វិញ្ញាសាសរសេរ។

  ***បញ្ជាក់÷*** ចំពោះកាលបរិច្ឆេទ និងទីកន្លែងប្រឡង នឹងជូនដំណឹងនៅពេលក្រោយ។

បេក្ខជន ឬបេក្ខនារី ដែលមានចំណាប់អារម្មណ៍និងគុណវុឌ្ឍិសមស្រប សូមធ្វើប្រវត្តិរូបសង្ខេប (CV) និង Cover Letter ដោយភ្ជាប់មកជាមួយនូវសញ្ញាបត្រ ឬលិខិតបញ្ជាក់ការសិក្សា ព្រមទាំងអត្តសញ្ញាណប័ណ្ណ (ច្បាប់ចម្លង) មកលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានអាសយដ្ឋានផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឬតាមរយៈសារអេឡិចត្រូនិច÷ Sim_Bunnarith@mef.gov.kh ឱ្យបានយ៉ាងយូរត្រឹមថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០២៤។

អាស្រ័យហេតុនេះ សូមនិស្សិត និងសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ អង្គារ ៥ រោច ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០២៤

**ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

សូមស្កេន QR Code

សម្រាប់ព័ត៌មានបន្ថែម ឬទំនាក់ទំនងលេខទូរស័ព្ទ÷

- ០១១ ៧២៨ ១៦៧